PESTECH

# ក្រុមហ៊ុន ផេសថិក (ខេមបូឌា) ម.ក

# របាយការណ៍ប្រចាំត្រីមាស

## ត្រីមាសទី ៤ សម្រាប់ឆ្នាំហិរញ្ញវត្ថុ

## ដែលបានបញ្ចប់នៅ

## ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣

PESTECH

# ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | | ត្រីមាសទី៤ ឆ្នាំ ២០២៣ (លានរៀល) | ឆ្នាំ ២០២២ (លានរៀល) | ឆ្នាំ ២០២១ (លានរៀល) |
|---|---|---|---|---|
| ទ្រព្យសកម្មសរុប | | ១ ១៩៩ ៤៨៦ | ១ ២០២ ២៨២ | ១ ១៦៦ ៨៨២ |
| បំណុលសរុប | | ១ ១០៨ ០៧៨ | ១ ០៩២ ២៦៦ | ១ ០៧២ ៩៨៥ |
| មូលធនសរុប | | ៩១ ៤០៨ | ១១០ ០១៦ | ៩៣ ៨៩៧ |
| **ចំណេញ/ (ខាត)** | | **ត្រីមាសទី៤ ឆ្នាំ ២០២៣ (លានរៀល)** | **ត្រីមាសទី៤ ឆ្នាំ ២០២២ (លានរៀល)** | **ត្រីមាសទី៤ ឆ្នាំ ២០២១ (លានរៀល)** |
| ចំណូលសរុប | | ៨ ៤៦៣ | ២៨ ៧៦៤ | ១១០ ៦៦៨ |
| (ខាត)/ចំណេញមុនបង់ពន្ធ | | (១០ ៧៩៤) | (៣ ០៣៣) | ៨ ២០៧ |
| ចំណេញប្រតិបត្តិការ | | (៦៥៣) | ២ ៤៩៩ | ១០ ៩០៩ |
| (ខាត)/ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | | (១០ ៣៣៦) | (៣ ៥៧៤) | ៦ ៧១២ |
| ចំណេញ/(ខាត)សរុបលម្អិត | | (៧ ៥០៤) | ១៨៣ | ៦ ២៥៨ |
| **អនុបាតហិរញ្ញវត្ថុ** | | **ត្រីមាសទី៤ ឆ្នាំ ២០២៣** | **ឆ្នាំ ២០២២** | **ឆ្នាំ ២០២១** |
| អនុបាតសាធនភាព | | (២,៤៦)% | ១,៦៨% | ២,៤០% |
| អនុបាតសាធនភាព (ប្រាក់កម្ចីទូទៅ)* | | (២៥,១៣)% | ១៥,៩៥% | ៤៩,៩៣% |
| អនុបាតសន្ទនីយភាព | អនុបាតចរន្ត | ០,៧៧ | ០,៩៣ | ០,៩០ |
| | អនុបាតចរន្តលឿន | ០,៧៥ | ០,៩២ | ០,៨៨ |
| | | **ត្រីមាសទី៤ ឆ្នាំ ២០២៣** | **ត្រីមាសទី៤ ឆ្នាំ ២០២២** | **ត្រីមាសទី៤ ឆ្នាំ ២០២១** |
| អនុបាតចំណេញភាព | អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | (០,៨៦)% | (០,៣០)% | ០,៥៨% |
| | អនុបាតចំណេញធៀបនឹងមូលធន | (១១,៣១)% | (៣,២៥)% | ៧,១៥% |
| | អនុបាតគម្លាតចំណេញដុល | ៤៩,៤០% | ២៤,៣៣% | ១៣,១៤% |
| | អនុបាតគម្លាតចំណេញភាព | (១២២,១៣)% | (១២,៤៣)% | ៦,០៦% |
| | ចំណេញក្នុងមួយឯកតាមូលបត្រ កម្មសិទ្ធិ(ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) (រៀល) | (១៣៧,៩១) | (៤៧,៦៩) | ៨៥,៣១ |
| អនុបាតលទ្ធភាពបង់ការប្រាក់ | | (០,០៥) | ០,៣០ | ១,៩១ |

PESTECH

* កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមិនរាប់បញ្ចូលលក្ខខណ្ឌកម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យាពេល ដែលមានកិច្ចព្រមព្រៀងទូទាត់ដោយផ្ទាល់ជាមួយអគ្គីសនីកម្ពុជា(EDC)។ កម្ចីសម្រាប់ដំណើរការអាជីវកម្មធម្មតាមានចំនួន ៣៦ ៧៩០ លានរៀល (ឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៤៣ ៨៧៩ លានរៀល) និង កម្ចីរយៈពេលវែង ដែលបានធានាដោយដំណើរការនៃគម្រោងទូទាត់ពន្យារពេលមានចំនួន ៣៣៨ ៩២៨ លានរៀលគិតត្រឹមថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣ (ឆ្នាំ ២០២២៖ ៣៧២ ៦៩២ លានរៀល) ។

PESTECH

# សមាសភាពក្រុមប្រឹក្សាភិបាល



PESTECH

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ជូនចំពោះភាគហ៊ុនិក

សម្ព័ន្ធក្រុមហ៊ុនមានកិត្តិយសបង្ហាញជូននូវលទ្ធផលហិរញ្ញវត្ថុសម្រាប់ត្រីមាសទីបួន (៤) ("Q៤" ឬ ត្រីមាស) នៃឆ្នាំហិរញ្ញវត្ថុ ("FY") ២០២៣។ គួរឲ្យសោកស្តាយ យើងនៅតែបន្តស្ថិតនៅក្រោមឥទ្ធិពលអវិជ្ជមានដែលកើតឡើងពីកត្តាខាងក្រៅផ្សេងៗ ដែលនាំមកនូវឱនភាពនៅក្នុងលទ្ធផលដែលបានរាយការណ៍សម្រាប់ត្រីមាសចុងក្រោយនៃឆ្នាំហិរញ្ញវត្ថុ ២០២៣។

ស្ថានភាពអត្រាតម្លៃកម្ចីខ្ពស់នៅតែបន្ត និងកម្រិតនៃអតិផរណាបានធ្វើឲ្យមានសម្ពាធយ៉ាងសំខាន់ទៅលើសម្ព័ន្ធក្រុមហ៊ុន ដោយដាក់កម្រិតលើភាពបត់បែននៃលំហូរសាច់ប្រាក់របស់យើង និងប៉ះពាល់ដោយប្រយោលដល់ប្រសិទ្ធភាពនៃការបំពេញអាជីវកម្ម។

ប្រាក់ចំណូលសរុបត្រូវបានកត់ត្រាត្រឹមចំនួន ៨ ៤៦៣ ពាន់លានរៀលក្នុងកំឡុងត្រីមាស បើធៀបទៅនឹង ២៨ ៧៦៤ ពាន់លានរៀល ក្នុងត្រីមាសដដែលសម្រាប់ការត្រួតពិនិត្យក្នុងឆ្នាំហិរញ្ញវត្ថុ ២០២២។ លទ្ធផលដែលមិនអាចជៀសរួចនេះ នឹងធ្វើឲ្យការបង្កើតប្រាក់ចំណូលបន្តធ្លាក់ចុះរហូតដល់លំហូរសាច់ប្រាក់របស់យើងមានភាពប្រសើរឡើងវិញ។

ប្រាក់ខាតប្រតិបត្តិការដែលមានចំនួន ៦៥៣ ពាន់លានរៀលត្រូវបានកត់ត្រាសម្រាប់Q៤ បើធៀបទៅនឹង ២ ៤៩៩ ពាន់លានរៀលនៃប្រាក់ចំណេញប្រតិបត្តិការ ក្នុងកំឡុងត្រីមាសទី៤ ឆ្នាំ២០២២។ ជាអកុសល ចំណូលទាបមិនអាចទប់ទល់នឹងការចំណាយប្រតិបត្តិការ ជាពិសេសការចំណាយថេរក្នុងត្រីមាសចុងក្រោយនៃឆ្នាំហិរញ្ញវត្ថុ ២០២៣ នេះ។ ក្នុងន័យនេះដែរ ប្រាក់ខាតក្រោយពេលបង់ពន្ធ ("LAT") ក៏បានកើនឡើងដល់ ១០ ៣៣៦ ពាន់លានរៀល បើធៀបនឹង ("LAT") ចំនួន ៣ ៥៧៤ ពាន់លានរៀល ក្នុងត្រីមាសដដែលសម្រាប់ការត្រួតពិនិត្យក្នុងឆ្នាំហិរញ្ញវត្ថុ ២០២២។ យើងគ្រាន់តែអាចរំពឹងថានឹងមានផលវិជ្ជមានបន្ថែមទៀតនៅពេលដែលស្ថានភាពអត្រាការប្រាក់កាន់តែប្រសើរ ហើយផលប៉ះពាល់អតិផរណាបានធូរស្រាល។

ក្នុងស្ថានភាពដ៏លំបាកនេះ គណៈគ្រប់គ្រងសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនមេ PESTECH International Berhad ("PIB") បានព្យាយាមរិះរកមធ្យោបាយដើម្បីស្រោចស្រង់ ហើយសង្ឃឹមថានឹងទទួលបានលទ្ធផលហិរញ្ញវត្ថុល្អប្រសើរសម្រាប់ឆ្នាំហិរញ្ញវត្ថុខាងមុខ។ យើងមានភាពវិជ្ជមានលើបញ្ហារឹតបន្តឹងដែលបានស្នើឡើងថ្មីៗនេះដែលបានប្រកាសនៅកម្រិត PIB នោះ PESTECH Group ទាំងមូលរួមទាំង PCL នឹងអាចទទួលបានអត្ថប្រយោជន៍នៃការគាំទ្រសហការគ្នាជាយថាហេតុពីសាជីវកម្មក្នុងឧស្សាហកម្មហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបង្កើនលទ្ធភាពហិរញ្ញវត្ថុ និងអាជីវកម្មរបស់យើង។

យើងឈានចូលទៅក្នុងឆ្នាំហិរញ្ញវត្ថុថ្មី សម្ព័ន្ធក្រុមហ៊ុនមានបំណងរៀបចំផែនការផ្គត់ផ្គង់របស់ខ្លួនឡើងវិញ ដើម្បីទទួលបានទំនុកចិត្តឡើងវិញពីអតិថិជន និងស្ថាប័នហិរញ្ញវត្ថុសម្រាប់ឱកាសថ្មីលើលទ្ធកម្មនៃគម្រោងថ្មី និងការផ្តល់ការគាំទ្រសម្រាប់ហិរញ្ញប្បទានចាំបាច់ដើម្បីធ្វើឲ្យការអនុវត្តគម្រោងប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាព។ ស្របជាមួយនោះ យើងសូមបញ្ជាក់សារជាថ្មីលើការប្តេជ្ញាចិត្តរបស់សម្ព័ន្ធក្រុមហ៊ុន ក្នុងការរក្សាជំហររបស់យើងក្នុងនាមជាអ្នកចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធថាមពលនៅកម្ពុជា។

ជាថ្មីម្តងទៀត យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះភាគហ៊ុនិក អតិថិជន អ្នកផ្គត់ផ្គង់ និងក្រុមការងារក្នុងប្រទេសកម្ពុជាតែងតែផ្តល់ការគាំទ្រឥតឈប់ឈរ ដែលជួយជម្រុញឲ្យក្រុមហ៊ុនឆ្ពោះទៅមុខ ទោះក្នុងកាលៈទេសៈណាក៏ដោយ។

អរគុណ

PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

PAUL LIM PAY CHUAN

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

PESTECH

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

ភាគហ៊ុនិកជាទីរាប់អាន

ឆ្នាំហិរញ្ញវត្ថុ ២០២៣ បានបង្ហាញថាជាឆ្នាំដ៏លំបាកមួយសម្រាប់សម្ព័ន្ធក្រុមហ៊ុនដោយសារការកេសាងប្រាក់ចំណូលមានភាពយឺតយ៉ាវ និងការចំណាយប្រតិបត្តិការកើនឡើង។ Q៤ នេះក៏មិនត្រូវបានរួចផុតពីផលប៉ះពាល់បែបនេះ ដែលបន្តកើតមានឡើងពេញមួយឆ្នាំហិរញ្ញវត្ថុនេះ។

លទ្ធផលហិរញ្ញវត្ថុប្រហែលជាមិនបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវទំហំនៃកិច្ចខិតខំប្រឹងប្រែងដែលក្រុមប្រតិបត្តិការក្នុងអំឡុងត្រីមាសនេះ ភាពឧស្សាហ៍ព្យាយាមក្នុងការគ្រប់គ្រងការចំណាយ និងការបែងចែកធនធានយ៉ាងប្រុងប្រយ័ត្ន ដើម្បីរក្សាប្រតិបត្តិការដែលមិនមានការខាតសម្រាប់សម្ព័ន្ធក្រុមហ៊ុន។

ជាលទ្ធផលនៃការកំណត់ផ្នែកហិរញ្ញវត្ថុដោយសារតែការកើនឡើងនៃការចំណាយលើការខ្ចី ការប្រតិបត្តិគម្រោងបានថយចុះយ៉ាងខ្លាំង ជាពិសេសក្នុងអំឡុងពេល Q៤ ។ ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងការទទួលគម្រោងដ៏ល្អដែលកំពុងកាន់កាប់ រួមជាមួយនឹងការអភិវឌ្ឍន៍សាជីវកម្មចុងក្រោយបំផុតដែលបានស្នើឡើងនៅកម្រិតក្រុមហ៊ុនមេរបស់ PCL គណៈគ្រប់គ្រងបានចាប់ផ្តើមទំនាក់ទំនងជាមួយស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធ និងដៃគូគម្រោងដើម្បីជាក់ឲ្យដំណើរការ ការអនុវត្តជាបន្តបន្ទាប់នៃគម្រោងដែលមានស្រាប់ និងការបន្តគម្រោងថ្មីដែលមានសក្តានុពល។

គណៈគ្រប់គ្រងសង្ឃឹមថានឹងជឿជាក់លើកំណត់ត្រាផ្លូវដ៏ធំទូលាយរបស់ក្រុមហ៊ុនក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនថាមពលដែលទ្រទ្រង់ដោយគ្រឿងចក្រដែលបំពាក់បានយ៉ាងល្អជាមួយនិងបទពិសោធន៍ជាច្រើនក្នុងការរចនា វិស្វកម្ម និងការអនុវត្ត លើគ្រឿងបរិក្ខារប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅលើដំបូល ដើម្បីផ្តល់ជូននូវការប្រតិបត្តិគម្រោងដ៏ទូលំទូលាយ និងប្រតិបត្តិការរយៈពេលវែង និងសេវាកម្មថែទាំដល់ទីផ្សារកកើតឡើងវិញដែលកំពុងរីកចម្រើននៅកម្ពុជា។ យើងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូបច្ចេកទេសក្នុងការផ្តល់នូវដំណោះស្រាយដែលអាចទុកចិត្តបាន និងចំណាយមានប្រសិទ្ធភាពសម្រាប់ថាមពលកកើតឡើងវិញជាមួយនឹងសក្តានុពលនៃការស្តុកទុក ដើម្បីធានាបាននូវការផ្គត់ផ្គង់ថាមពលបៃតងប្រកបដោយនិរន្តរភាព និងគ្មានការខាតដល់សហគមន៍កម្ពុជា ជាមួយនឹងការខាតតិចតួចបំផុតដល់ប្រព័ន្ធបណ្តាញអគ្គិសនីជាតិ។

ចំពោះម្ចាស់ភាគហ៊ុនរបស់យើង យើងរក្សាភាពសុទិដ្ឋិនិយមលើការបំពេញការងារនាពេលអនាគតរបស់ PCL ។ យើងនឹងរក្សាជំហរដោយការប្តេជ្ញាចិត្តដូចដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍ប្រចាំត្រីមាសមុនរបស់យើងក្នុងការបន្តផ្តោតទៅលើគម្រោងចំណូលហើសដោយសមហេតុផល ជាមួយនឹងតម្រូវការចំណាយដើមទុនតិចតួចបំផុត។ នេះនឹងជួយក្នុងការបង្កើតលំហូរសាច់ប្រាក់វិជ្ជមានដើម្បីជម្រុញសម្ព័ន្ធក្រុមហ៊ុនឆ្ពោះទៅមុខយ៉ាងប្រាកដប្រជា។

ជាចុងក្រោយ យើងចង់បង្ហាញពីការដឹងគុណរបស់យើងចំពោះភាគហ៊ុនិក អតិថិជន អ្នកផ្គត់ផ្គង់ និងក្រុមការងាររបស់យើង សម្រាប់ទំនុកចិត្ត និងការគាំទ្រដើម្បីការអភិវឌ្ឍន៍របស់យើង។

សូមអរគុណ

ព្រះរាជាណាចក្រកម្ពុជា
ប៉េសធិក (ខេមបូឌា) ម.ក
PESTECH (CAMBODIA) PLC
KINGDOM OF CAMBODIA

LIAN FATT JUAN

**នាយកប្រតិបត្តិ**

ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

PESTECH

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... i

សមាសភាពក្រុមប្រឹក្សាភិបាល ..... ii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... iii

សេចក្តីថ្លែងប្រធាននាយកប្រតិបត្តិ ..... iv

**ផ្នែកទី១៖ ព័ត៌មានទូទៅនៃក្រុមហ៊ុន ចុះបញ្ជី**

ក. អត្តសញ្ញាណក្រុមហ៊ុនចុះបញ្ជី
ខ. សកម្មភាពអាជីវកម្ម
គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

**ផ្នែកទី២៖ ព័ត៌មានពីលទ្ធផលប្រតិបត្តិការអាជីវកម្ម**

ក. លទ្ធផលប្រតិបត្តិការជីវកម្ម
ខ. រចនាសម្ព័ន្ធចំណូល

**ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានត្រួតពិនិត្រឡើងវិញដោយសវនកឯករាជ្យ**

**ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង**

ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ
ខ. កត្តាសំខាន់ៗដែលជះឥទ្ធិពលលើផលចំណេញ
គ. ការប្រែប្រួលសំខាន់ៗលើការលក់ និងប្រាក់ចំណូល
ឃ. ផលប៉ះពាល់នៃអត្រាប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងតម្លៃទំនិញ
ង. ផលប៉ះពាល់នៃអតិផរណា
ច. សេដ្ឋកិច្ច សារពើពន្ធ គោលនយោបាយរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

**ផ្នែកទី៥៖ ព័ត៌មានសំខាន់ៗដ៏ទៃផ្សេងទៀតសម្រាប់ការការពារវិនិយោគិន**

ហត្ថលេខារបស់អភិបាលនៃក្រុមហ៊ុនចុះបញ្ជី

PESTECH

## ផ្នែកទី១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក. អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាភាសាខ្មែរ | **ផេសថិក (ខេមបូឌា) ម.ក** |
| ជាអក្សរឡាតាំង | **PESTECH (CAMBODIA) PLC** |
| លេខកូដស្តង់ដារ | KH១០០០១៤០០០៩ |
| និមិត្តសញ្ញា | ផថខ |
| អាសយដ្ឋាន | អគារលេខ ៣៥ ជាន់ទី១០ ផ្លូវម៉ៅសេទុង ភូមិ៩ សង្កាត់បឹងកេងកងទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | +៨៥៥ ២៣ ៨៨២ ១០៥ |
| លេខទូរសារ | +៨៥៥ ២៣ ៨៨២ ១០៦ |
| គេហទំព័រ | www.pestech.com.kh |
| អ៊ីមែល៖ | info@pestech.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០០៩៥៧ ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាប័ណ្ណអាជីវកម្ម | ៣២៦ ប្រក.ជនស.អសណ ចេញដោយ ជនស ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ |
| សេចក្តីសម្រេចអនុញ្ញាត្ត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានលេខ | ១៧១/២០ គ.ម.គ/ស.ស.រ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០២០ ចេញដោយ គណៈកម្មការមូលបត្រកម្ពុជា (បច្ចុប្បន្នជានិយ័តករមូលបត្រកម្ពុជា "នមក") |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | លោក Paul Lim Pay Chuan |

### ខ. ប្រភេទអាជីវកម្ម

ផថខ បានរួមចំណែកជាចម្បងក្នុងការផ្តល់ វិស័យវិស្វកម្ម និងដំណោះស្រាយបច្ចេកទេសនៃប្រព័ន្ធអគ្គីសនីដ៏ទូលំទូលាយសម្រាប់៖

- ការរចនាប្លង់ លទ្ធកម្ម  សាងសង់ តម្លើង និងការដាក់ឱ្យប្រើប្រាស់អនុស្ថានីយ៍ HV និង EHV ខ្សែបញ្ជូនអគ្គីសនី HV និង EHV ព្រមទាំងប្រព័ន្ធខ្សែកាបអគ្គីសនីក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គីសនីផងដែរ
- កិច្ចដំណើរការ និងការថែទាំ ("**O&M**") ខ្សែបញ្ជូនអគ្គីសនី និងអនុស្ថានីយ៍ និង
- ការធ្វើពាណិជ្ជកម្ម បរិក្ខារប្រព័ន្ធអគ្គីសនី និងឧបករណ៍ ជាកម្មសិទ្ធិ និងមិនមែនជាកម្មសិទ្ធិ

## គ. ព្រឹត្តិការណ៍សំខាន់ប្រចាំត្រីមាស

### ១. កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ

នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣ ផថខ បានរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកវិសាមញ្ញ នៅសណ្ឋាគារ សាន់ & មូន រ៉ិវ៉ែសាយ។ មហាសន្និបាតនេះមានភាគហ៊ុនិក និងអាណត្តិគាហកៈចូលរួមដែលមានចំនួនភាគហ៊ុនសរុបចំនួន ៧១ ១៧៧ ៤៥៨ ហ៊ុន។ ភាគហ៊ុនិកបានបោះឆ្នោត និងអនុម័តលើការមិនបែងចែកភាគលាភសម្រាប់ឆ្នាំហិរញ្ញវត្ថុដែលត្រូវបញ្ចប់នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣។ ខាងក្រោមនេះជាកម្រងរូបភាពខ្លះៗរបស់ភាគហ៊ុនិកនិងសកម្មភាពអំឡុងពេលមហាសន្និបាត។











### ២. កម្មវិធីពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃក្នុងឆ្នាំ២០២៣

នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣ ផថខ រួមជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ ឯកឧត្តម កែវ រតនៈ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីប្រទេសម៉ាឡេស៊ីចំនួន ៣០ នាក់ បានរៀបចំកម្មវិធីពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃជូនប្រជាពលរដ្ឋរស់នៅក្នុងស្រុកក្រគរ និងស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។ កម្មវិធីពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃនេះបានរៀបចំចំនួនពីរថ្ងៃ ដែលបានទទួលពិនិត្យ និងពិគ្រោះយោបល់ជូនអ្នកជំងឺ លើសពី ២ ០០០ នាក់ ក្នុងស្រុកទាំងពីរ។ ខាងក្រោមនេះជាកម្រងរូបភាពខ្លះៗនៃសកម្មភាពរបស់បុគ្គលិក និងក្រុមគ្រូពេទ្យស្ម័គ្រចិត្តអំឡុងពេលទទួលពិនិត្យ និងពិគ្រោះយោបល់ជូនអ្នកជំងឺ។









# ផ្នែកទី២៖ ព័ត៌មានអំពីលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម

## ក. លទ្ធផលនៃប្រតិបត្តិការអាជីវកម្មតាមផ្នែក

នៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ សកម្មភាពប្រតិបត្តិការ និងសកម្មភាពថែទាំ ("O&M") បានក្លាយជាការរួមចំណែកដ៏សំខាន់ចំពោះប្រាក់ចំណូលដែលមានទឹកប្រាក់ចំនួន ៤ ២៨១ លានរៀល (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៤ ២៣១ លានរៀល) ដែលស្មើនឹងប្រមាណ ៥០,៦% (ឆ្នាំហិរញ្ញវត្ថុ ២០២២៖ ១៤,៧%) នៃប្រាក់ចំណូលសរុប។ ការកើនឡើងនៃប្រាក់ចំណូលបានរួមចំណែកពីសកម្មភាព ("O&M") គឺកើតឡើងពីការលក់ផ្គត់ផ្គង់នូវ

សម្ភារៈរបស់ ("O&M") ក្នុងអំឡុងត្រីមាស បន្ទាប់ពីការបញ្ចប់កិច្ចសន្យា ("O&M") នៅខេត្តក្រចេះ។ ការកើនឡើងប្រាក់ចំណូលបានមកពីការរួមចំណែកពីសកម្មភាព ("O&M") ដែលគាំទ្របន្ថែមដោយការទទួលស្គាល់ប្រាក់ចំណូលខ្ពស់ បើប្រៀបធៀបទៅនឹងឆ្នាំហិរញ្ញវត្ថុមុនដែលជាលទ្ធផលនៃការផ្លាស់ប្តូរតម្លៃកិច្ចសន្យារបស់ គម្រោង ("O&M")នៅក្រុងព្រះសីហនុ។

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ ("EPCC") សម្រាប់បណ្តាញអគ្គីសនី និង អនុស្ថានីយ៍ ដែលមានទឹកប្រាក់ចំនួន ៤ ១៨២ លានរៀល (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ២៤ ៥៣៣ លានរៀល) ក្នុងត្រីមាសក្រោមការត្រួតពិនិត្យឡើងវិញ ដែលស្មើនឹងប្រមាណ ៤៩,៤% (ឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៨៥,៣%) នៃចំណូលសរុប។

ក្នុងកំឡុងត្រីមាសនេះ សម្ព័ន្ធក្រុមហ៊ុនបានទទួលស្គាល់ចំណូលហិរញ្ញប្បទានមានចំនួន ២ ៤៥១ លានរៀល (ត្រីមាសទីបួន ឆ្នាំ ២០២២៖ ២ ៦៩៥ លានរៀល) សម្រាប់កិច្ចសន្យាជាក់លាក់ជាមួយអតិថិជន ស្របតាមការអនុលោមស្តង់ដា របាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("CIFRS") ១៥ ។ ចំណូលហិរញ្ញប្បទានគឺជាផ្នែកមួយនៃប្រាក់ចំណូលសរុបរបស់យើងនៅក្នុងសម្ព័ន្ធ។

## ខ. របនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទីបួន ឆ្នាំ២០២៣ | | ត្រីមាសទីបួន ឆ្នាំ២០២២ | | ត្រីមាសទីបួន ឆ្នាំ២០២១ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ("EPCC) កិច្ចសន្យាសម្រាប់អគ្គីសនី និងអនុស្ថានីយ៍ | ៤ ១៨២ | ៤៩,៤ | ២៤ ៥៣៣ | ៨៥,៣ | ១០៧ ៤៧៨ | ៩៧,១ |
| ២ | ប្រតិបត្តិការ និងសេវាថែទាំ | ៤ ២៨១ | ៥០,៦ | ៤ ២៣១ | ១៤,៧ | ៣ ១៩០ | ២,៩ |
| | **ប្រាក់ចំណូលសរុប** | **៨ ៤៦៣** | **១០០,០** | **២៨ ៧៦៤** | **១០០,០** | **១១០ ៦៦៨** | **១០០,០** |

| ល.រ | ប្រភពចំណូលកិច្ចសន្យា | ត្រីមាសទីបួន ឆ្នាំ ២០២៣ | | ត្រីមាសទីបួន ឆ្នាំ ២០២២ | | ត្រីមាសទីបួន ឆ្នាំ ២០២១ | |
|---|---|---|---|---|---|---|---|
| | | លានរៀល | ភាគរយ | លានរៀល | ភាគរយ | លានរៀល | ភាគរយ |
| ១ | ប្រាក់ចំណូល | ៨ ៤៦៣ | ៧៧,៥ | ២៨ ៧៦៤ | ៩១,៤ | ១១០ ៦៦៨ | ៩៧,៤ |
| ២ | ចំណូលហិរញ្ញប្បទានសម្រាប់ទ្រព្យសកម្មកិច្ចសន្យា | ២ ៤៥១ | ២២,៥ | ២ ៦៩៥ | ៨,៦ | ២ ៩៧០ | ២,៦ |
| | **ប្រាក់ចំណូលកិច្ចសន្យាសរុប** | **១០ ៩១៤** | **១០០,០** | **៣១ ៤៥៩** | **១០០,០** | **១១៣ ៦៣៨** | **១០០,០** |

## ផ្នែកទី៣៖ របាយការណ៍ហិរញ្ញវត្ថុពិនិត្យដោយសវនករខាងក្រៅ

សូមយោងទៅតាមរបាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយត្រូវបានធ្វើការត្រួតពិនិត្រឡើងវិញរួចរាល់ហើយដោយសវនករឯករាជ្យ។

## ផ្នែកទី៤៖ កិច្ចពិភាក្សា និងវិភាគរបស់គណៈគ្រប់គ្រង (“MD&A”)

### ក. ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១. ការវិភាគចំណូល

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣ បានកត់ត្រាត្រឹម ៨ ៤៦៣ លានរៀល ដោយថយចុះចំនួន ២០ ៣០១ លានរៀល ឬ ៧០,៦% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនដែលបានកត់ត្រាចំនួនត្រឹម ២៨ ៧៦៤ លានរៀល។ បម្រែបម្រួលនៃប្រាក់ចំណូលបានឆ្លុះបញ្ចាំងពីវឌ្ឍភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នដែលស្ថិតនៅក្រោមការត្រួតពិនិត្យ គឺបណ្តាលមកពីការបញ្ចប់គម្រោងនៃភាគខាងកើតសៀមរាប នាខែមីនា ឆ្នាំ២០២៣ និងវឌ្ឍនភាពនៃគម្រោងទាបជាង ដែលត្រូវបានទទួលស្គាល់ដោយគម្រោងព្រំដែនឡាវ និងគម្រោងតាតៃបើប្រៀបធៀបនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

### ២. ការវិភាគចំណូលតាមផ្នែក

នៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ សកម្មភាពប្រតិបត្តិការ និងសកម្មភាពថែទាំ (“O&M”) បានក្លាយជាការរួមចំណែកដ៏សំខាន់ចំពោះប្រាក់ចំណូលដែលមានទឹកប្រាក់ចំនួន ៤ ២៨១ លានរៀល (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៤ ២៣១ លានរៀល) ដែលស្មើនឹងប្រមាណ ៥០,៦% (ឆ្នាំហិរញ្ញវត្ថុ ២០២២៖ ១៤,៧%) នៃប្រាក់ចំណូលសរុប។ ការកើនឡើងនៃប្រាក់ចំណូលបានរួមចំណែកពីសកម្មភាព (“O&M”) គឺកើតឡើងពីការលក់ ផ្គាច់នូវសម្ភារះរបស់ (“O&M”) ក្នុងអំឡុងត្រីមាស បន្ទាប់ពីការបញ្ចប់កិច្ចសន្យា (“O&M”) នៅខេត្តក្រចេះ។ការកើនឡើងប្រាក់ចំណូលបានមកពីការរួមចំណែកពីសកម្មភាព (“O&M”) ដែលគាំទ្របន្ថែមដោយការទទួលស្គាល់ប្រាក់ចំណូលខ្ពស់ បើប្រៀបធៀបទៅនឹងឆ្នាំហិរញ្ញវត្ថុមុនដែលជាលទ្ធផលនៃការផ្លាស់ប្តូរតម្លៃកិច្ចសន្យារបស់ គម្រោង (“O&M”)នៅក្រុងព្រះសីហនុ។

កិច្ចសន្យាលើ វិស្វកម្ម លទ្ធកម្ម ការសាងសង់ និងការដាក់អោយដំណើរការ (“EPCC”) សម្រាប់បណ្តាញអគ្គិសនី និងអនុស្ថានីយ៍ ដែលមានទឹកប្រាក់ចំនួន ៤ ១៨២ លានរៀល (ត្រីមាសទីបួននៃឆ្នាំហិរញ្ញវត្ថុ ២០២២៖ ២៤ ៥៣៣ លានរៀល) ក្នុងត្រីមាសក្រោមការត្រួតពិនិត្យឡើងវិញ ដែលស្មើនឹងប្រមាណ ៤៩,៤% (ឆ្នាំហិរញ្ញវត្ថុ ២០២២៖ ៨៥,៣%) នៃចំណូលសរុប។

### ៣. ការវិភាគគម្លាតចំណេញដុល

ចំណេញដុលនៅក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បានកត់ត្រាមានចំនួនត្រឹម ៤៩,៤% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនមានចំនួន ២៤,៣% ដោយកើនឡើងចំនួន ២៥,១%។ ចំណេញដុលខ្ពស់ជាងក្នុងត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ គឺបណ្តាលមកពីការរួមចំណែកនៃប្រាក់ចំណូលដ៏សំខាន់ដែលផ្លាស់ប្តូរពី EPCC ទៅជា O&M ដែល O&M តែងតែមានគម្លាតចំណេញដុលខ្ពស់ជាងបើប្រៀបធៀប និង EPCC ។យ៉ាងណាក៏ដោយ គម្លាតចំណេញដុល គឺស្ថិតនៅក្នុងការរំពឹងទុក របស់សម្ព័ន្ធក្រុមហ៊ុន។

### ៤. ការវិភាគចំណេញមុនបង់ពន្ធ

ខាតមុនបង់ពន្ធសម្រាប់ត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ ត្រូវបានកត់ត្រាត្រឹម ១០ ៧៩៤ លានរៀល បើប្រៀបធៀបទៅនឹងការខាតមុនពេលបង់ពន្ធដែលមានចំនួន ៣ ០៣៣ លានរៀលក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន ដោយថយចុះចំនួន ៧ ៧៦១ លានរៀល ឬ ២៥៥,៩% ។ ខាតមុនបង់ពន្ធជាកត្តាចម្បងដែលបានមកពីការទទួលស្គាល់ប្រាក់ចំណូលទាបសម្រាប់ត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញ បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន និងថ្លៃដើមហិរញ្ញប្បទានខ្ពស់ដោយសារកាការដំឡើងអត្រាការប្រាក់។

### ៥. ការវិភាគ(ខាត)/ចំណេញក្នុងការិយបរិច្ឆេទ

ការខាតក្រោយដកពន្ធនៃត្រីមាសបច្ចុប្បន្នក្រោមការត្រួតពិនិត្យឡើងវិញមានចំនួនត្រឹម ១០ ៣៣៦ លានរៀល បើប្រៀបធៀបទៅនឹងខាតក្រោយដកពន្ធមានចំនួន ៣ ៥៧៤ លានរៀល ក្នុងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនដោយថយចុះមានចំនួន ៦ ៧៦២ លានរៀល ឬ ១៨៩,២% ។

### ខ. កត្តាសំខាន់ដែលជះឥទ្ធិពលលើប្រាក់ចំណេញ

អំឡុងពេលក្រោមការត្រួតពិនិត្យឡើងវិញនេះ មិនមានកត្តាសំខាន់ៗណាមួយដែលជះឥទ្ធិពលលើប្រាក់ចំណេញរបស់ប្រតិបត្តិការចំពោះសម្ព័ន្ធក្រុមហ៊ុនឡើយ។

### គ. ការប្រែប្រួលសំខាន់ៗនៃការលក់ និងប្រាក់ចំណេញ

ចំណូលសរុបសម្រាប់បីខែនៃរយៈពេលហិរញ្ញវត្ថុ ដែលបានបញ្ចប់នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ បានកត់ត្រាត្រឹម ៨ ៤៦៣ លានរៀល ដោយថយចុះចំនួន ២០ ៣០១ លានរៀល ឬ ៧០,៦% បើប្រៀបធៀបទៅនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុនដែលបានកត់ត្រាចំនួនត្រឹម ២៨ ៧៦៤ លានរៀល។ បម្រែបម្រួលនៃប្រាក់ចំណូលបានឆ្លុះបញ្ចាំង

ពីវឌ្ឍភាពនៃការអនុវត្តគម្រោងផ្សេងៗក្នុងប្រទេសកម្ពុជា។ ប្រាក់ចំណូលទាបនៅក្នុងត្រីមាសបច្ចុប្បន្នដែលស្ថិតនៅក្រោមការត្រួតពិនិត្យ គឺបណ្តាលមកពីការបញ្ចប់គម្រោងនៃភាគខាងកើតសៀមរាប នាខែមីនា ឆ្នាំ២០២៣ និងវឌ្ឍនភាពនៃគម្រោងទាបជាងដែលត្រូវបានទទួលស្គាល់ដោយគម្រោងព្រំដែនឡាវ និងគម្រោងតាតៃបើប្រៀបធៀបនឹងត្រីមាសនៃឆ្នាំហិរញ្ញវត្ថុមុន។

### ឃ. ផលប៉ះពាល់នៃការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងតម្លៃទំនិញ

ការកើនឡើងនៃអត្រា LIBOR នាពេលថ្មីៗនេះបានបង្កើនចំណាយហិរញ្ញវត្ថុរបស់សម្ព័ន្ធក្រុមហ៊ុន។ទោះបីជាមានការកើនឡើងនៃអត្រា LIBOR ក៏ដោយក៏សម្ព័ន្ធក្រុមហ៊ុនបានចុះកិច្ចសន្យាលើគម្លាតអត្រាការប្រាក់នៃកិច្ចសន្យាបញ្ចាំ ផលប៉ះពាល់របស់សម្ព័ន្ធក្រុមហ៊ុនពីហានិភ័យអត្រាការប្រាក់លើឥណទានមានការកំណត់ដែលអនុញ្ញាតអោយសម្ព័ន្ធក្រុមហ៊ុនបង្កើនប្រាក់កម្ចីក្នុងអត្រាទីផ្សារប្តូរទៅជាអត្រាថេរ។ ក្រៅពីការលើកឡើងខាងលើនេះ ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដែលបណ្តាលមកពីការប្តូររូបិយបណ្ណបរទេស អត្រាការប្រាក់ និងការឡើងចុះនៃតម្លៃទំនិញនោះទេ។

### ង. ផលប៉ះពាល់នៃអតិផរណា

ការចំណាយសម្រាប់អាជីវកម្មរបស់យើង គឺដោយសារផលប៉ះពាល់នៃអតិផរណាដែលមានចំនួនប្រហែល ៧០% នៃចំណូលរបស់យើង។ ទោះបីជាយ៉ាងណាក៏ដោយ អតិផរណានៅក្នុងប្រទេសកម្ពុជា មានចំនួន ១,៩% (គិតត្រឹមថ្ងៃ

ទី ៣០ ខែ មិថុនា ឆ្នាំ ២០២៣ ប្រភព៖ :អត្រាអតិផរណានៅត្រីមាសទីមួយរបស់កម្ពុជាធ្លាក់មកត្រឹម ១,៩ % ) ដែលបានបង្កផលប៉ះពាល់ប្រហែល ១,៣៤% ប៉ុណ្ណោះ ចំពោះប្រាក់ចំណេញរបស់យើង ។ ក្រៅពីការលើកឡើងខាងលើនេះ ពុំមានផលប៉ះពាល់សំខាន់ៗផ្សេងទៀត ដែលបណ្តាលមកពីអតិផរណានោះទេ។

## ច. គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ រូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ពុំមានបម្រែបម្រួលសំខាន់ៗនៅក្នុងគោលនយោបាយសេដ្ឋកិច្ច/សារពើពន្ធ/សាច់ប្រាក់របស់រាជរដ្ឋាភិបាល ឬ កត្តានានា ដែលមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះលទ្ធផលហិរញ្ញវត្ថុនៅក្នុងអំឡុងឆ្នាំនេះនោះទេ។

## ផ្នែកទី ៥៖ ព័ត៌មានសំខាន់ៗដទៃទៀតសម្រាប់ការការពារវិនិយោគិន

ពុំមានព័ត៌មានដែលចាំបាច់ផ្សេងទៀតសម្រាប់ការការពារវិនិយោគិន។

PESTECH

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

(ត្រូវចុះហត្ថលេខាដោយ ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលយ៉ាងតិច ២ នាក់)

ថ្ងៃចន្ទ ១៣ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧

ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣

បានអាន និងឯកភាព

**ហត្ថលេខា**

PAUL LIM PAY CHUAN

ប្រធានក្រុមប្រឹក្សាភិបាល